**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៤៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលរចនាសម្ព័ន្ធនៃនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មកជានាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ និង បង្កើតនាយកដ្ឋានផែនការនិងស្ថិតិ ចំណុះអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងមុខងារសាធារណៈ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមុខងារសាធារណៈ។



www.pheakdeylaw.com

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងកែសម្រួលរចនាសម្ព័ន្ធរបស់នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មកជានាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ និងបង្កើតនាយកដ្ឋានផែនការនិងស្ថិតិ ចំណុះអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងមុខងារសាធារណៈ ដើម្បីបំពេញបន្ថែមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅ៖

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់នាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ។
- រៀបចំតួនាទីនិងភារកិច្ចរបស់នាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ។
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលក្នុងការដឹកនាំគ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក ផែនការ ហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៃក្រសួងមុខងារសាធារណៈ។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

## ផ្នែកទី១
## នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់

**មាត្រា៤.-**

នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដោយមានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំផែនការហិរញ្ញវត្ថុរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងរបស់ក្រសួង



www.pheakdeylaw.com

- រៀបចំផែនការយុទ្ធសាស្ត្រថវិកានិងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ព្រមទាំងតាមដានវិលើកពីការប្រតិបត្តិ
- ប្រមូលផ្តុំនិងសម្របសម្រួលជំពូកថវិកា និង ការចំណាយរបស់ក្រសួង
- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គត់ផ្គង់សម្ភារនិងបរិក្ខាររបស់ក្រសួង
- រៀបចំសំណើសុំថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយ និង បើកផ្តល់បែងចែកថវិកាជូនអង្គភាពថវិការបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានដ្ឋាននិងយានយន្តរបស់រដ្ឋ ដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈនិងគ្រឿងបន្លាស់
- ទទួលនិងបែងចែក សម្ភារនិងបរិក្ខារជូនដល់អង្គភាពក្រោមឱវាទ
- ធ្វើកិច្ចបញ្ជិកាគណនេយ្យជាប្រចាំនូវសលាកប័ត្រនិងគណនេយ្យរូបធាតុ
- សហការនិងអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា
- តាមដាននិងរំលឹកការគ្រប់គ្រងគណនីពិសេស
- គ្រប់គ្រងបន្ទុកគណនីនិងត្រួតពិនិត្យបច្ចេកទេសនៃការអនុវត្តលទ្ធកម្មសាធារណៈ របស់ក្រសួង
- សហការជាមួយអ្នកផ្តល់ជំនួយនិងប្រតិបត្តិការជំនួយជាតិ-អន្តរជាតិ
- សហការជាមួយអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ
- រៀបចំលិខិតបទដ្ឋាននានា សម្រាប់ណែនាំដល់ការងារគ្រប់គ្រងនិងប្រើប្រាស់ថវិកាគ្រប់ជំពូក
- កសាងនិងពង្រឹងសមត្ថភាពមន្ត្រីជំនាញនៃអង្គភាពថវិកាក្រោមឱវាទក្រសួង ពាក់ព័ន្ធនឹងការអនុវត្តកិច្ចការហិរញ្ញវត្ថុនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង

នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

## ផ្នែកទី២

## នាយកដ្ឋានផែនការនិងស្ថិតិ

**មាត្រា៥.-**

នាយកដ្ឋានផែនការនិងស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដោយមានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំនិងអនុវត្តការងារពាក់ព័ន្ធនឹងស្ថិតិតាមការកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន



www.pheakdeylaw.com

- សម្របសម្រួលទិន្នន័យស្ថិតិជាមួយអង្គភាពនានាក្រោមឱវាទក្រសួង ដើម្បីចងក្រងស្ថិតិរួមរបស់ក្រសួង
- វិភាគ សិក្សាស្រាវជ្រាវ និងរៀបចំទិន្នន័យ កំណត់កម្មវិធីសកម្មភាព និងធ្វើគម្រោងផែនការសកម្មភាពការងារ ដោយសហការជាមួយអង្គភាពក្រោមឱវាទក្រសួង
- កសាងទស្សនទាន យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីអភិវឌ្ឍន៍ក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ រយៈពេលខ្លី រយៈមធ្យម និងរយៈពេលវែងដោយសម្របសម្រួលជាមួយអង្គភាពនានាក្រោមឱវាទក្រសួង
- រៀបចំចងក្រង ប្រព័ន្ធទិន្នន័យស្ថិតិទូទៅនិងស្ថិតិផ្លូវការរបស់ក្រសួង
- ចូលរួមគ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងការងារស្ថិតិរបស់ក្រសួង
- សិក្សាស្រាវជ្រាវនិងរៀបចំចងក្រងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍរបស់ក្រសួង
- ធ្វើសម្រង់ព័ត៌មានផែនការសកម្មភាព ដែលត្រូវអនុវត្តប្រចាំឆ្នាំ របស់អង្គភាពក្រោមឱវាទក្រសួង
- រៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទក្រសួង
- សិក្សាបញ្ហាប្រឈម លើការអនុវត្តផែនការសកម្មភាព និង កម្មវិធីគម្រោងនានា របស់អង្គភាពក្រោមឱវាទក្រសួង
- រៀបចំកែលម្អ អភិវឌ្ឍ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព កម្មវិធីគម្រោងនានា របស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួង
- គ្រប់គ្រងនិងចងក្រងឯកសារស្តីពីគម្រោងជំនួយ និង ស្ថានភាពនៃការអនុវត្តគម្រោងរបស់អ្នកផ្តល់ជំនួយក្នុងវិស័យមុខងារសាធារណៈ
- រៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ ដោយសហការជាមួយអង្គភាពដែលពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង

នាយកដ្ឋានផែនការនិងស្ថិតិ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា៦ ._**

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ការិយាល័យនៃនាយកដ្ឋាននានាចំណុះឱ្យអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

**មាត្រា៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



www.pheakdeylaw.com

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩ កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com